ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ:០១៧/រ.ទ.ភ

ថ្ងៃពុធ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤

## សេចក្ដីជូនដំណឹងលើកទី២
## ស្ដីពី
## ការអញ្ជើញចូលរួមបង្ហាញចំណាប់អារម្មណ៍

សូមអញ្ជើញក្រុមហ៊ុន/យានដ្ឋាន ដែលមានលក្ខណៈសម្បត្តិ ចូលរួមបង្ហាញចំណាប់អារម្មណ៍ស្ដីពីការផ្ដល់សេវាជួសជុលរថយន្ត សម្រាប់រយៈពេល១ឆ្នាំ។

ក្រុមហ៊ុន/យានដ្ឋាន ទាំងអស់ដែលមានចំណាប់អារម្មណ៍ អាចទាក់ទងជាមួយអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ឯកសារបង្ហាញពីចំណាប់អារម្មណ៍ ត្រូវបានផ្ដល់ជូនក្រុមហ៊ុន/យានដ្ឋានដោយមិនគិតថ្លៃ ក្នុងរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃព្រហស្បតិ៍ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤ ដល់ថ្ងៃពុធ ទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ។

ក្រុមហ៊ុន/យានដ្ឋានត្រូវបំពេញឯកសារបង្ហាញពីចំណាប់អារម្មណ៍ហើយប្រគល់ជូនអង្គភាពលទ្ធកម្ម ចាប់ពីថ្ងៃព្រហស្បតិ៍ ទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ដល់ថ្ងៃពុធ ទី០៦ ខែមីនា ឆ្នាំ២០២៤ រៀងរាល់ម៉ោងធ្វើការ។

សំណើបង្ហាញពីចំណាប់អារម្មណ៍របស់ក្រុមហ៊ុន/យានដ្ឋានទាំងអស់មិនតម្រូវឱ្យមានប្រាក់កក់ធានាឡើយ។ ក្រុមហ៊ុន/យានដ្ឋានដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើបង្ហាញពីចំណាប់អារម្មណ៍បានតែមួយគត់។

ក្រុមហ៊ុន/យានដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងត្រូវបានអញ្ជើញដើម្បីអនុវត្តនីតិវិធីបន្តក្នុងការផ្ដល់សេវាជួសជុលរថយន្តសម្រាប់រយៈពេល១ឆ្នាំ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

សម្រាប់រាល់ព័ត៌មានលំអិតសូមអញ្ជើញទាក់ទងអង្គភាពលទ្ធកម្មដូចមានអាសយដ្ឋានខាងលើ ឬ តាមទូរស័ព្ទលេខ: ០១៧ ៨១១ ៩១១។

ជ. គណៈកម្មាធិការលទ្ធកម្ម
អនុប្រធាន

ជូ ផល្លា

"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ